ក

មាតិកា

I_រាជរដ្ឋាភិបាល

១_អនុក្រឹត្យ

១១-១១-២០០៤	-អនុក្រឹត្យ លេខ ៥៩៤ អនក្រ.បក ស្តីពីការលុបឈ្មោះ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	២៧២១
១១-១១-២០០៤	-អនុក្រឹត្យ លេខ ៥៩៥ អនក្រ.បក ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	២៧២៣
១១-១១-២០០៤	-អនុក្រឹត្យ លេខ ៥៩៦ អនក្រ.បក ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	២៧២៥
១១-១១-២០០៤	-អនុក្រឹត្យ លេខ ៥៩៧ អនក្រ.បក ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	២៧២៧
១១-១១-២០០៤	-អនុក្រឹត្យ លេខ ៥៩៨ អនក្រ.បក ស្តីពីការលុបឈ្មោះ និង តែងតាំងមុខតំណែងមន្ត្រីរាជការ	២៧២៩
១១-១១-២០០៤	-អនុក្រឹត្យ លេខ ៥៩៩ អនក្រ.បក ស្តីពីការផ្ទេរ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	២៧៣១
១១-១១-២០០៤	-អនុក្រឹត្យ លេខ ៦០០ អនក្រ.បក ស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ	២៧៣៣

២_សេចក្តីសំរេច

២៥-១១-២០០៤	-សេចក្តីសំរេច លេខ ៧៤០ សសរ ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល	២៧៣៥

៣_សារាចរណែនាំ

២៣-១១-២០០៤	-សារាចរណែនាំ លេខ ១២ សរណន ស្តីពីកាតព្វកិច្ចកសាងរាជកិច្ច	២៧៣៦

II_ការងារបណ្តាក្រសួង

១_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៤-១១-២០០៤	-ប្រកាស លេខ ២៣៨ MOC/M 2004 ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃ និងជ្រើសរើសសេវាពិគ្រោះយោបល់ក្នុងក្របខ័ណ្ឌ នៃគំរោងកិច្ចសំរួលពាណិជ្ជកម្ម និងការប្រកួតប្រជែង	២៧៣៨

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងការពារជាតិ

៣០-១១-២០០៤	-សេចក្តីសំរេច លេខ ០៤២ សសរ /២០០៤ ស្តីពីការចេញប័ណ្ណអាវុធខ្លី ផ្លាកលេខសំគាល់សំភារៈសឹក ប័ណ្ណបើកបរ ប័ណ្ណសំគាល់ និងផ្លាកលេខយានយន្តគ្រប់ប្រភេទ	២៧៤១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៩៤ អនក្រ.បក

អនុក្រឹត្យ

ស្ដីពី

ការលុបឈ្មោះ និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្ដីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្ដូរក្របខ័ណ្ឌ ឋានន្តរសក្ដិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១ :

ត្រូវបានលុបឈ្មោះលោក **តឿន ណារ៉េត** ឋានន្តរសក្ដិ អនុមន្ត្រី ថ្នាក់លេខ ៦ អភិបាលស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលបានទទួលមរណភាព ចេញពីក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ។

មាត្រា ២ :

ត្រូវបានប្រគល់ភារកិច្ចជូនលោក **គង់ ម៉ែ** ឋានន្តរសក្តិ វរៈសេនីយ៍ឯក ក្របខ័ណ្ឌក្រសួងការពារជាតិ ឱ្យមកទទួលភារកិច្ចជា អភិបាលស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ។

មាត្រា ៣ :

លោកវរៈសេនីយ៍ឯក **គង់ ម៉ែ** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំ នៃបៀវត្ស របស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

មាត្រា ៤ :

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥ :

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>ចម្លងជូន</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

(ដើម្បីជូនជ្រាប)

ដូចមាត្រា ៥ (ដើម្បីអនុវត្ត)

- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៤៣៤ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១ :

ត្រូវបានប្រគល់ភារកិច្ចជូនលោក **ឡាយ សុខា** ឋានន្តរសក្តិ នាយកក្រមការ ថ្នាក់លេខ ៣ ឱ្យទទួលភារកិច្ចជាអភិបាលស្រុកបាទី ខេត្តតាកែវ ។

មាត្រា ២ :

លោក **ឡាយ សុខា** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។

មាត្រា ៣ :

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ :

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៤ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងការអនុវត្តនី ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១ :

ត្រូវបានប្រគល់ភារកិច្ចជូនលោក **ជឹត ថៃ** ឋានន្តរសក្តិ នាយក្រមការ ថ្នាក់លេខ ៣ អោយទទួលភារកិច្ចជាអភិបាលស្រុកកំពង់សិលា ខេត្តកោះកុង ។

មាត្រា ២ :

លោក **ជឹក ថុន** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំ នៃបៀវត្ស របស់មន្ត្រីរាជការស៊ីវិល ។

មាត្រា ៣ :

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ :

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>ចម្លងជូន</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (<u>ដើម្បីជូនជ្រាប</u>)*
- *ដូចមាត្រា ៤ (<u>ដើម្បីអនុវត្ត</u>)*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៤១៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១ :

ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ០៣រូប ក្នុងរចនាសម្ព័ន្ធសាលាស្រុក ខេត្តក្រចេះ ដូចមានរាយនាមខាងក្រោម :

១- លោក **ភឿ ស៊ីយ៉េម** ឋានន្តរសក្តិ នាយក្រមការ ថ្នាក់លេខ ៤ អោយទទួលភារកិច្ចជាអភិបាលស្រុកក្រចេះ

២- លោក **តុខ ហ៊ុល** ឋានន្តរសក្តិ នាយក្រមការ ថ្នាក់លេខ ៤ អោយទទួលភារកិច្ចជា អភិបាលស្រុកសំបូរ

៣- លោក **អ៊ុច សាគុំ** អនុប្រធានមន្ទីរកិច្ចការនារីខេត្ត ក្របខ័ណ្ឌក្រសួងកិច្ចការនារី ឱ្យមកទទួលភារកិច្ចជា អភិបាលស្រុកស្នួល ខេត្តក្រចេះ ។

មាត្រា ២ :

លោក **ហៀ ស៊ីយ៉េម** និង លោក **តុខ ហ៊ុល** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្ស របស់មន្ត្រីរាជការស៊ីវិល ។

មាត្រា ៣ :

លោក **អ៊ុច សាគុំ** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្ស របស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

មាត្រា ៤ :

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥ :

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>ចម្លងជូន</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (<u>ដើម្បីជូនជ្រាប</u>)*
- *ដូចមាត្រា ៥ (<u>ដើម្បីអនុវត្ត</u>)*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៤១៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការលុបឈ្មោះ និង តែងតាំងមុខតំណែងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១ :

ត្រូវបានលុបឈ្មោះលោក នួន ឈឿន ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៥ អភិបាលស្រុកព្រៃឈរ ខេត្តកំពង់ចាម ដែលបានទទួលមរណភាព ចេញពីក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ។

មាត្រា ២ :

តែងតាំងមុខតំណែងលោក **ស្រី សារឿន** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ ជាអភិបាលស្រុកព្រៃឈរ ខេត្តកំពង់ចាម ។

មាត្រា ៣ :

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ :

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
  ដើម្បីជូនជ្រាប
- *ដូចមាត្រា ៤ ដើម្បីអនុវត្ត*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា　　　　　ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៥៧៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការផ្ទេរ និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
  បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
  បានឃើញព្រះរាជក្រមលេខ ១៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១ :

ត្រូវបានផ្ទេរភារកិច្ចលោក **ផេង សារិត** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៥ ពីអភិបាលស្រុកថាឡាបរិវ៉ាត់ ឱ្យមកទទួលភារកិច្ចជា អភិបាលស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង ។

មាត្រា ២ :

ត្រូវបានប្រគល់ភារកិច្ចជូនលោក **ឈឹម ចេនា** មន្ត្រី នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទាខេត្ត ក្របខ័ណ្ឌក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឱ្យមកទទួលភារកិច្ចជា អភិបាលស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ។

មាត្រា ៣ :

លោក **ឈឹម ទេឆា** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្ស របស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

មាត្រា ៤ :

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥ :

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ វិច្ឆិកា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :

- *ក្រសួងព្រះបរមរាជវាំង*
  អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
  អគ្គលេខាធិការដ្ឋានរដ្ឋសភា
  អគ្គលេខាធិការរាជរដ្ឋាភិបាល
  ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  ដើម្បីជូនជ្រាប
- *ដូចមាត្រា ៥ ដើម្បីអនុវត្ត*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ២០០ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមុខតំណែងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤ ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .

សម្រេច

មាត្រា ១ :

តែងតាំងមុខតំណែងមន្ត្រីរាជការចំនួន ០៣រូប នៅអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និង នគរបាល ចំណុះទីស្តីការក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **គុណ ធីរក្ស** ឋានន្តរសក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៦ ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ។

២ ឯកឧត្តម **ឆ្លុង គឹមឆុន** ឋានន្តរសក្តិ ឧត្តមសេនីយ៍ទោ អត្តលេខ ០០៦៥ ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន កិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ។

៣- លោក **ឈឹម គឹមឈាង** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៧ ជាអធិការ នៃអធិការដ្ឋានកិច្ចការនយោបាយ និង រដ្ឋបាល ។

មាត្រា ២ :

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ :

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤

ហ៊ុន សែន

ចម្លងជូន :

- *ក្រសួងព្រះបរមរាជវាំង*
  អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
  អគ្គលេខាធិការដ្ឋានរដ្ឋសភា
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
  ដើម្បីជូនជ្រាប
- *ដូចមាត្រា ៣ ដើម្បីអនុវត្ត*
  ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៩៧៤ សសរ

សេចក្តីសំរេច

ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

យោងតាមសារចាំបាច់ [illegible] រាជរដ្ឋាភិបាល

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលកម្ពុជា ឡាវ មីយ៉ាន់ម៉ា-វៀតណាម កិច្ចប្រជុំកំពូលអាស៊ានលើកទី ១០ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធនានា ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងវៀងចន្ទ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចាប់ពីថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤ រហូតដល់សម្តេចនាយករដ្ឋមន្ត្រី អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- [illegible] រដ្ឋមន្ត្រី
- [illegible]
- [illegible]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ..០២៧..សរណន.

សារាចរណែនាំ

ស្តីពី

ភារកិច្ចរក្សាទុករាជកិច្ច

* * *

មាត្រា ៩៣ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៣ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី តម្រូវអោយរាជរដ្ឋាភិបាលផ្សព្វផ្សាយនូវគ្រប់បទដ្ឋានដល់សាធារណៈជនតាមរយៈនៃសៀវភៅរាជកិច្ច ។ តាមច្បាប់អ្វីដែលសាធារណៈជន ពុំបានដឹងឮ មិនអាចត្រូវយកមកអនុវត្តបានទេ ។

ចំណុចនេះ ហាក់ដូចជាមិនត្រូវបានបណ្តាក្រសួង និងស្ថាប័ននានាចាប់អារម្មណ៍ពិតប្រាកដសោះ ។ អំណើះតទៅ រាជរដ្ឋាភិបាលក្នុងគោលបំណងពង្រឹងនីតិរដ្ឋ សម្រេចចិត្តថានឹងធ្វើគ្រប់កិច្ចការដើម្បីបំពេញចំណុចខ្វះខាតនេះ ដោយសុំអោយបណ្តាក្រសួង និងស្ថាប័នទាំងឡាយអនុវត្តអោយបានត្រឹមត្រូវនូវអនុសាសន៍ ដូចខាងក្រោម :

១- គ្រប់បណ្តាក្រសួងនិងស្ថាប័នដែលមានសមត្ថកិច្ចចេញបទដ្ឋាន ត្រូវផ្ញើមកទីស្តីការគណៈរដ្ឋមន្ត្រីនូវគ្រប់បទដ្ឋានដែលមានភាពទូទៅនិងសំរាប់អនុវត្តទូទាំងប្រទេស ដោយមិនរាប់បញ្ចូលប្រកាសរដ្ឋមន្ត្រីតែងតាំងមន្ត្រីរាជការក្នុងបរិវេណក្រសួង ដែលមិនទាមទារអោយចុះផ្សាយក្នុងរាជកិច្ចកំរិតជាតិទេ ។

២- ទីស្តីការគណៈរដ្ឋមន្ត្រី និងចាត់ចែងការបោះពុម្ពផ្សាយរាជកិច្ច ដែលមានចុះបទដ្ឋានណាដែលមានកំរិតទូទៅ និងសំរាប់អនុវត្តទូទាំងប្រទេស ។

៣- តាមរយៈក្រសួងមហាផ្ទៃ និងអភិបាល ខេត្ត ក្រុង ស្រុក ខ័ណ្ឌ មេឃុំ និងចៅសង្កាត់ គ្រប់ទំព័ររាជកិច្ច ត្រូវបានបិទផ្សព្វផ្សាយនៅគ្រប់សាលាឃុំ សង្កាត់ ។

៤- ដើម្បីអោយបទដ្ឋានទាំងអស់មានតម្លៃគតិយុត្តិ ដែលមានវិសាលភាពអនុវត្តទូទាំងប្រទេសនោះ គឺរាល់លិខិតបទដ្ឋានទាំងឡាយណាដែលត្រូវបានបោះពុម្ពចងក្រងជាសៀវភៅរាជកិច្ច ទើបចាត់ទុកជាលិខិតផ្លូវការរបស់រដ្ឋ ។

៥- ទីស្តីការគណៈរដ្ឋមន្ត្រី អញ្ជើញគ្រប់ក្រសួង និងស្ថាប័នមកចុះកិច្ចសន្យាជារាជកិច្ច ដើម្បីក្រសួងយកទៅផ្សព្វផ្សាយក្នុងបរិវេណក្រសួង ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង-ស្ថាប័ន ខេត្ត-ក្រុង ត្រូវយកចិត្តទុកដាក់អនុវត្តតាមស្មារតី និងខ្លឹមសារនៃសារាចរណែនាំនេះ អោយមានប្រសិទ្ធភាព និងទទួលបានលទ្ធផលជាវិជ្ជមាន ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No ៧៣៤ MOC M 2004

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៤

ប្រកាស
ស្តីពី
ការបង្កើតគណៈកម្មការវាយតម្លៃ និងជ្រើសរើសសេវាពិគ្រោះយោបល់ ក្នុងក្របខ័ណ្ឌនៃគំរោងកិច្ចសំរួលពាណិជ្ជកម្ម និងការប្រកួតប្រជែង

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធានអនុគណៈកម្មការអចិន្ត្រៃយ៍កិច្ចសំរួលពាណិជ្ជកម្ម

បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២, នស. ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការ រៀបចំ និង ប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស រកម ០១៩៦ ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

យោងសេចក្តីសំរេចលេខ ៤៤ សសរ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើត គណៈកម្មការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន

- យោងសេចក្តីសំរេចលេខ ៤៦ សសរ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើត អនុគណៈកម្មការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន
- យោងប្រកាសលេខ ២២៨៩/០៤ ក.អ.ក ចុះថ្ងៃទី១៩ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើត ក្រុមកំណែទំរង់កិច្ចសំរួលពាណិជ្ជកម្ម ។

សំរេច

ប្រការ១: ត្រូវបានបង្កើតគណៈកម្មការ វាយតំលៃ និងជ្រើសរើសសេវាពិគ្រោះយោបល់ ដើម្បីអនុវត្តគំរោង កំណែទំរង់កិច្ចសំរួលពាណិជ្ជកម្ម ដែលមានសមាសភាពដូចខាងក្រោម:

១- ឯកឧត្តម **គឹម ស៊ីថន** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ប្រធានក្រុមកំណែទំរង់ កិច្ចសំរួលពាណិជ្ជកម្ម ប្រធាន

២ លោក **លី ផវណ្ណារ** អគ្គនាយករងបច្ចេកទេស ក្រសួងពាណិជ្ជកម្ម អនុប្រធាន

៣ - លោក **វ័ន់ត សុគីន** ប្រធាននាយកដ្ឋានគណនេយ្យ ក្រសួងពាណិជ្ជកម្ម សមាជិក

៤ តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

៥- លោក **ប៉ែន សុទិជាតិ** អនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា ក្រសួងពាណិជ្ជកម្ម សមាជិក

៦ លោក **ឌរ ស៊ី** ជំនួយការឯកឧត្តមទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សមាជិក

ប្រការ២: គណៈកម្មការវាយតំលៃ និងជ្រើសរើស សេវាពិគ្រោះយោបល់នេះ មានភារៈកិច្ចដូចតទៅ :

១ ពិនិត្យ និង វាយតំលៃលើសមត្ថភាព និង គុណភាពនៃក្រុមហ៊ុនពិគ្រោះយោបល់ ដែលបានដាក់ពាក្យសុំដេញថ្លៃ ដើម្បីផ្តល់សេវាពិគ្រោះយោបល់នៅក្រសួងពាណិជ្ជកម្ម

២ ជ្រើសរើស និងរៀបចំតាមលំដាប់លេខរៀង នូវក្រុមហ៊ុនផ្តល់សេវាពិគ្រោះយោបល់ទៅតាមមុខជំនាញរបស់ក្រុមហ៊ុននីមួយៗ លើគំរោងការងារទាំង ០៦ ចំណុចដែលរាជរដ្ឋាភិបាលបានប្រកាសរកសេវា ពិគ្រោះយោបល់ គឺ :

- ការពិនិត្យឡើងវិញនូវតួនាទីជាយុទ្ធសាស្ត្ររបស់នាយកដ្ឋានកាំកងត្រួល
- ការវិភាគអំពីសំណូមពរសំរាប់ការអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិជ្ជាពត៌មាន និង គមនាគមន៍
- ផែនការអភិវឌ្ឍន៍ធនធានមនុស្ស
- ប្រព័ន្ធវាស់សង់ការអនុវត្តន៍
- ផែនការកសាងសមត្ថភាពនៃការចូលរួមរបស់ផ្នែកឯកជនក្នុងហេដ្ឋារចនាសម្ព័ន្ធ
- ការបង្កើតនូវសៀវភៅណែនាំការអនុវត្តន៍

៣ សហការជាមួយម្ចាស់ជំនួយ ដើម្បីចរះកិច្ចសន្យាជូលក្រុមហ៊ុនទាំងឡាយណាដែលត្រូវបានជ្រើសរើសអោយផ្តល់សេវាពិគ្រោះយោបល់

៤ រាយការណ៍ជូនឯកឧត្តមប្រធានអនុគណៈកម្មការអចិន្ត្រៃយ៍ ទទួលបន្ទុកកំណែទំរង់កិច្ចសំរួលពាណិជ្ជកម្ម នូវឈ្មោះក្រុមហ៊ុនផ្តល់សេវាពិគ្រោះយោបល់ដែលត្រូវបានជ្រើសរើសឱ្យផ្តល់សេវាពិគ្រោះយោបល់តាមជំនាញនីមួយៗ នៃចំណុចទាំង ០៦ ខាងលើ ។

ប្រការ៣: គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ជាផ្លូវការនូវត្រារបស់ក្រសួងពាណិជ្ជកម្ម ។

Ministry of Commerce # 20 A & B Preah Norodom Boulevard Phnom Penh 12205, Kingdom of Cambodia
Minister's Mobile Phone (855-12) 821888 Facsimile (855-23) 213288
RL http www.moc.gov.kh E-Mail champrasidh@hotmail.com
Staff's Mobile Phones (855-12) 933 323 881223 Facsimile (855-23) 426396

ប្រការ៤: អគ្គនាយកបច្ចេកទេស អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ នាយិកាខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្ត ប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

ចំលងជូន

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានគណៈកម្មការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន
- ដូចប្រការ៤ ដើម្បីអនុវត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 (Kingdom of Cambodia)
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones: (855-12) 933 323 / 881223 Facsimile: (855-23) 426396

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

លេខ ០៤៦២ / ស.ស.រ / ២០០៤

សេចក្តីសម្រេច

ស្តីពី

ការចេញប័ណ្ណអាវុធខ្លី ផ្លាកលេខសំគាល់សំភារៈសឹក ប័ណ្ណបើកបរ ប័ណ្ណសំគាល់ និងផ្លាកលេខយានយន្តគ្រប់ប្រភេទ

សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម /០៧០៤ /០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស /រកត /០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញក្រឹត្យលេខ ១១ក្រ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ១៩៩២ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការផ្តន្ទាទោសការកាន់អាវុធ និងការពាក់សំលៀកបំពាក់ឯកសណ្ឋានដោយខុសពីបទបញ្ជា
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ

- បានឃើញអនុក្រឹត្យលេខ ៣៨អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យ ការនាំចូល ការផលិត ការលក់ ការទិញដូរ ការចែកចាយ និងការប្រើប្រាស់អាវុធ ជាតិផ្ទុះគ្រប់ប្រភេទ
- បានឃើញអនុក្រឹត្យលេខ ៧៧អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការចេញផ្លាកលេខសំគាល់យានជំនិះ
- តាមសេចក្តីត្រូវការចាំបាច់របស់ក្រសួងការពារជាតិ

សម្រេច

ប្រការ១ : ប្រគល់សិទ្ធិអោយអគ្គនាយកដ្ឋានសំភារៈបច្ចេកទេសក្រសួងការពារជាតិ មានសមត្ថកិច្ចគ្រប់គ្រងត្រួតពិនិត្យអំពីការចេញប័ណ្ណអាវុធខ្លី ផ្លាកលេខសំភារៈសឹក ប័ណ្ណបើកបរ ប័ណ្ណសំគាល់ និងផ្លាកលេខយានយន្តគ្រប់ប្រភេទនៅក្នុងកងយោធពលខេមរភូមិន្ទ ។

ប្រការ ២ : អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ក្រសួងការពារជាតិត្រូវ :

- ធ្វើសេចក្តីកំណត់ណែនាំអនុវត្តនូវរាល់ខ្លឹមសារក្នុងប្រការ១ ដាក់ជូនក្រសួងការពារជាតិ ពិនិត្យសំរេច និងផ្សព្វផ្សាយអនុវត្ត ។
- ចាត់តាំងបែងចែកកំណត់តួនាទីភារកិច្ចអោយស្ថាប័ន កងឯកភាពក្រោមឱវាទគោរពអនុវត្តខ្លឹមសារប្រការ១ទទួលបានប្រសិទ្ធិភាពខ្ពស់ ។

ប្រការ ៣ : ការចុះហត្ថលេខា និងបោះត្រាលើប័ណ្ណអាវុធខ្លី (ជាលក្ខណៈផ្ទាល់ខ្លួន និងសមូហភាព) ប័ណ្ណបើកបរ និងប័ណ្ណសំគាល់យានយន្តគ្រប់ប្រភេទជាសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ក្រសួងការពារជាតិ ។

ប្រការ ៤ : រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសំរេចនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ៥ : អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ស្ថាប័នកងឯកភាពក្រោមឱវាទក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ ត្រូវគោរពអនុវត្ត សេចក្ដីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៤

សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

នាយឧ.ផ្កាយមាស៤ **ទៀ_បាញ់** នាយឧ.ផ្កាយមាស៤.**ញឹក_ប៊ុនឆៃ**

<u>ចម្លងជូន</u>

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- កងរាជអាវុធហត្ថលើផ្ទៃប្រទេស

  (ដើម្បីជូនជ្រាប)

- អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ក្រសួងការពារជាតិ

  (ដើម្បីចាត់តាំងអនុវត្ត)

- ឯកសារ កាលប្បវត្តិ